ក	ភ្នាក់ងារបើកផ្តល់	លោក ខេក ប៊ុង			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ប៉ាន់ ចាន់ថន			
៥៥	តំបន់សឹករងសៀមរាប		ភ្នំពេញ	សៀមរាប	
ក	ភ្នាក់ងារបើកផ្តល់	លោក ពៅ សិប្ញរ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក អ៊ិត ស៊ីវិចិត្រ			
៥៦	តំបន់សឹករងឧត្តរមានជ័យ		ភ្នំពេញ	សៀមរាប	
ក	ភ្នាក់ងារបើកផ្តល់	លោក ប៊ុង ណារិន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ជុំ រក្សាលិន			
៥៧	កងពលធំលេខ ៣		ភ្នំពេញ	សៀមរាប	
ក	ភ្នាក់ងារបើកផ្តល់	លោក ភួង វិចិត្រ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ង៉ែត សំនាង			
៥៨	កងពលធំលេខ ៩		ភ្នំពេញ	សៀមរាប	
ក	ភ្នាក់ងារបើកផ្តល់	លោក ឃិន សារុធ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក វ៉ាន់ ថា			
៥៩	កងពលធំលេខ ១១		ភ្នំពេញ	សៀមរាប	

ក	ភ្នាក់ងារបើកផ្តល់	លោក ភ្នំ ប៊ុនរឿន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឈុយ បុណ្ណា			
៦០	តំបន់សឹករងកំពង់ធំ		ភ្នំពេញ	កំពង់ធំ	
ក	ភ្នាក់ងារបើកផ្តល់	លោក សូ សារិន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឆួយ សុផល			
៦១	តំបន់សឹករងព្រះវិហារ		ភ្នំពេញ	ព្រះវិហារ	
ក	ភ្នាក់ងារបើកផ្តល់	លោក សេង សារឿន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឧន់ ប៊ូរ៉េត			
៦២	តំបន់សឹករងបាត់ដំបង		ភ្នំពេញ	បាត់ដំបង	
ក	ភ្នាក់ងារបើកផ្តល់	លោក ឯក មុន្នីរ៉ាន់			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឈឿម វិចេក			
៦៣	កងពលលេខ ៦		ភ្នំពេញ	បាត់ដំបង	
ក	ភ្នាក់ងារបើកផ្តល់	លោក ខែម សារ៉ុម			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ចាំង សុវណ្ណ			
៦៤	កងពលធំលេខ ៤		ភ្នំពេញ	បាត់ដំបង	
ក	ភ្នាក់ងារបើកផ្តល់	លោក លឹម ហួរ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឧង ទូលាយ			
៦៥	កងពលធំលេខ ១២		ភ្នំពេញ	បន្ទាយមានជ័យ	
ក	ភ្នាក់ងារបើកផ្តល់	លោក ជឹម ស៊ី			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឈឿត លាង			

៦៦	តំបន់សីករងពោធិសាត់		ភ្នំពេញ	ពោធិសាត់	
ក	ភ្នាក់ងារបើកផ្តល់	លោក សោម ម៉ាធន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក គង ជា			
៦៧	តំបន់សីករងកណ្តាល		ភ្នំពេញ	កណ្តាល	
ក	ភ្នាក់ងារបើកផ្តល់	លោក សួស សារ៉ាត			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក សាយ សារ៉ា			
៦៨	តំបន់សីករងកំពង់ឆ្នាំង		ភ្នំពេញ	កំពង់ឆ្នាំង	
ក	ភ្នាក់ងារបើកផ្តល់	លោក ពៅ ប៊ុនថុល			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក អ៊ុង សំអុល			
៦៩	យោធភូមិភាគ ៤		ភ្នំពេញ	សៀមរាប	
ក	ភ្នាក់ងារបើកផ្តល់	លោក រស់ សារិន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក សំ សួរ			
៧០	យោធភូមិភាគ ៥		ភ្នំពេញ	បាត់ដំបង	
ក	ភ្នាក់ងារបើកផ្តល់	លោក អួន គន្ធ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ឡុច ឈឿត			
៧១	តំបន់សីករងប៉ៃលិន		ភ្នំពេញ	បាត់ដំបង	
ក	ភ្នាក់ងារបើកផ្តល់	លោក ទេស កែ			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក លិច សុខន			

៧២	តំបន់សឹករងបន្ទាយមានជ័យ		ភ្នំពេញ	បន្ទាយមានជ័យ	
ក	ភ្នាក់ងារបើកផ្តល់	លោក សេរ សាន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក កួរ ឈិន			
៧៣	កងពលធំលេខ ៨		ភ្នំពេញ	ពោធិសាត់	
ក	ភ្នាក់ងារបើកផ្តល់	លោក គីម សេងងន			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក គីម សំបូរ			
៧៤	កងពលធំលេខ ៧		ភ្នំពេញ	បន្ទាយមានជ័យ	
ក	ភ្នាក់ងារបើកផ្តល់	លោក ឆេង សុផល			
ខ	ភ្នាក់ងារបើកជំនួស	លោក ផាន់ សារឿន			
៧៥	ក្រុមសុខាភិបាល		ភ្នំពេញ		
ក	ភ្នាក់ងារបើកផ្តល់	លោក ឡុង សំណាង			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោកស្រី វង្ស សុភាព			
៧៦	នាយកដ្ឋានឃោសនា		ភ្នំពេញ		
ក	ភ្នាក់ងារបើកផ្តល់	លោក វិន សារ៉ានី			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ចាន់ សារ៉ាដ			
៧៧	សាលានាយទាហានរង		ភ្នំពេញ		
ក	ភ្នាក់ងារបើកផ្តល់	លោក មាស សុធី			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ស៊ី សុណ្ណារ៉េត			
៧៨	ការិយាល័យយោធាតំបន់		ភ្នំពេញ		

ក	ភ្នាក់ងារបើកផ្តល់	លោក ខោល សំអាត			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ញ៉ែមហាណាត			
៧៩	កងពលលេខ ១		ភ្នំពេញ		
ក	ភ្នាក់ងារបើកផ្តល់	លោក គង់ ច័ន្ទរិដ្ឋី			
ខ	ភ្នាក់ងារបើកផ្តល់ជំនួស	លោក ម៉ែវ ស៊ីណូ			

ប្រការ ៣ : ភ្នាក់ងារបើកផ្តល់ទាំងអស់ដូចមានរាយនាមក្នុងប្រការ ២ ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ (ឬ រតនាគារខេត្ត-ក្រុង) ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រី រាជការនៃកងយោធពលខេមរភូមិន្ទ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការនៃកងយោធពលខេមរភូមិន្ទ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច រតនាគាជាតិព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស់ និងក្រសួងការពារជាតិព្រមទាំងមន្ត្រីរាជការ នៃកងយោធពលខេមរភូមិន្ទដូចក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខានិងត្រា
ឧត្តមសេនីយ៍ឯក **ទៀ បាញ់** ឧត្តមសេនីយ៍ឯក **ឌា ឈីរ៉ាត់**

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១៨ សហវ.ប្រ.ក.ម

ស្តីពីភារកិច្ចសិទ្ធិនិងរចនាសម្ព័ន្ធរបស់

ការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០២ន.ស/៩៤ ចុះថ្ងៃទី២០ កក្កដា ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនសរកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ ន.សរកត/១០៩៤/៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.សរកម ០១៩៦-១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០៣៩ សហ.វ ប្រកម ស្តីពីការបង្កើតការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារចំណុះមន្ទីរ ចុះថ្ងៃទី២៨ ខែ កុម្ភៈ ១៩៩៥
- បានឃើញតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារ ជាការិយាល័យចំណុះ មន្ទីរនៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ២ : ការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារ មាននាទីភារកិច្ចនិងសិទ្ធិដូចតទៅ :

-សហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការផ្តួចផ្តើមគំនិតនិងរៀបចំអត្ថបទដែលមានចរិក ជាច្បាប់និងបទបញ្ញាដែលពាក់ព័ន្ធនិងប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ

-តាមដានការអនុវត្តន៍ និងបទដ្ឋាននានា

-រួមចំណែកក្នុងការតាក់តែងអនុក្រឹត្យ សារាចរណែនាំដើម្បីអនុវត្តអត្ថបទដែលមានចរិត ជា

-តាក់តែងរបាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីអំពីឥទ្ធិពល នៃការអនុវត្តន៍ច្បាប់ អនុក្រឹត្យ និងសារាចរណែនាំដែលពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ

-តាមដានការធ្វើអោយស៊ីសង្វាក់គ្នាជាមួយប្រព័ន្ធសារពើពន្ធក្នុងសមាគមអាស៊ានសំរបសំរួល ប្រព័ន្ធច្បាប់ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-សំរបសំរួលប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ ទៅនឹងប្រព័ន្ធច្បាប់នានា

-គ្រប់គ្រងបណ្ណាល័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមដាន និងជំរុញការផ្សព្វផ្សាយអត្ថបទដែលមានចរិតជាច្បាប់របស់ក្រសួងសេដ្ឋកិច្ចនិង ប៉ នៅក្នុងរាជកិច្ច

ប្រការ ៣ : ការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាច្រើនរូបទៀតជាជំនួយការ ។

ប្រការ ៤ : ការិយាល័យនីតិកម្មហិរញ្ញវត្ថុ និងតំកល់ឯកសារ ត្រូវបែងចែកជាផ្នែក ដូចតទៅ :

១/ផ្នែកសំរបសំរួល :

-សំរបសំរួលការសិក្សា	-ប្រមូលផ្តុំនិងពិនិត្យសេចក្តីព្រាងអត្ថបទច្បាប់និងបទបញ្ញា
-ទំនាក់ទំនងសាធារណៈ	-ការសិក្សាទូទៅ

២/ផ្នែកគយ និងរដ្ឋាករ :

-តារាងពន្ធគយ	-សេចក្តីព្រាងប្រកាស និងសារាចរនានា
-ច្បាប់គយ	-ការចងក្រងឯកសារ
-នីតិវិធីគយ	

៣/ផ្នែកពន្ធដារ :

-អាករប្រើប្រាស់	-ពន្ធលើដីធ្លី
-ពន្ធលើផលរបរ	-អាករលើតំលៃបន្ថែម (VAT)
-ពន្ធលើប្រាក់ចំណេញ	-ពន្ធចុះបញ្ជី

–អាករពិសេស –ការចងក្រងឯកសារ

៤/ផ្នែកទំនាក់ទំនងអន្តរជាតិ :

សិក្សាប្រៀបធៀបប្រព័ន្ធច្បាប់ហិរញ្ញវត្ថុកម្ពុជាជាមួយប្រព័ន្ធច្បាប់ហិរញ្ញវត្ថុ បរទេស ពិសេសប្រទេសសមាជិកសមាគមអាស៊ាន ។

៥/បណ្ណាល័យ :

៦/ផ្នែកផ្សេងៗ :

–ថវិកា –ក្រុមហ៊ុនជាតិធានារ៉ាប់រង

–ទ្រព្យរដ្ឋ –វិនិយោគ

–ហិរញ្ញកិច្ច –លទ្ធកម្មសាធារណៈ

–ហិរញ្ញវត្ថុក្រៅប្រទេស –អាស៊ាន

–ធនាគារជាតិ –អធិការកិច្ច

–របបគណនេយ្យ –ការចងក្រងឯកសារ

ប្រការ៥ : ប្រធាននាយកដ្ឋាន និងអង្គភាពទាំងអស់ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៨១ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ១ : អនុញ្ញាតអោយលោក **ឈរ ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៧៥៤៦ ភ.ព ចុះថ្ងៃទី ២៥ -៨-៩១ អាស័យដ្ឋានបច្ចុប្បន្នផ្ទះសង់ថ្មី ៥ ផ្លូវលេខ ២២១ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញបន្តដំណើរការសិប្បកម្មផលិតធំប៉ុង សញ្ញា « D.D »នៅក្នុងទីតាំងផ្ទះសង់ថ្មី ផ្លូវលេខ២២១ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៨២ ឧក.ប្រក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ខ៊ា ពេជ្ជរត្នី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៩៧៩០៣ ក.ណ ចុះថ្ងៃទី១៣ -០១-៩៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិក្ពមសំណរក្រោម ឃុំក្ពមសំណរ ស្រុកលើកដែក ខេត្តកណ្តា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើមនៅក្នុងទីតាំង ភូមិក្ពមសំណរក្រោម ឃុំក្ពមសំណរ ស្រុកលើកដែក ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ៨៤ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ១ : អនុញ្ញាតអោយលោក **ខា សារិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២១៨៥៩៤ ភ.ម ចុះថ្ងៃទី៣១ -០៣-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវលេខ៦៣ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្ម ផលិតឥដ្ឋក្បឿង នៅក្នុងទីតាំងភូមិ២ សង្កាត់ច្រាំងចំរេះ២ ខ័ណ្ឌឫស្សីកែវរាជធានី ភ្នំពេញ ។

ប្រការ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៨៥ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ុ សួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៤៥៩៨ ភ.ព ចុះថ្ងៃទី ១៤ -៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៤៧៣ អឺ០ ផ្លូវលេខ ៩៣ សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ បន្តដំណើរការ

រោងជាងក្រឡឹង និង ជួសជុលរថយន្ត នៅក្នុងទីតាំង ផ្ទះលេខ ៤៧៣ ផ្លូវលេខ៩៣ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៨៦ ឧក.ប្រក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សៀ ម៉ុនយី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០៩៨៣២៩ ភ.ព ចុះថ្ងៃទី ៦ -៤-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២១ សេ ផ្លូវលេខ ៣៦៣ សង្កាត់ផ្សារអំពៅទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការ ឧស្សាហកម្មតូចផលិតសំភារៈប្រើប្រាស់អំពីអាលុយមីញ៉ូមសញ្ញា «ព្រាបនិងផែនដី » នៅក្នុងទីតាំង ផ្ទះលេខ២ ផ្លូវលេខ៣៣៧ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **សៀ ម៉ុនយី** ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល សំភារៈប្រើប្រាស់ពីអាលុយមីញ៉ូម សញ្ញា «ព្រាប និងផែនដី » ស្របតាមគំរូសញ្ញាសំគាល់ ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៨៧ ផក.ប្រក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ១ : អនុញ្ញាតអោយលោក **ពៀម ចន្ថា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៣៣២៧ ភ.ព ចុះថ្ងៃទី ២៦ -៣-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៣៣ អឺ០ ផ្លូវលេខ១០៧ សង្កាត់អូរឫស្សីទី១ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបន្តដំណើរការរោងជាង ក្រឡឹង នៅក្នុងទីតាំង ផ្ទះលេខ ១៣៣ អឺ០ ផ្លូវលេខ១០៧ សង្កាត់ឫស្សីទី១ ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២: ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះ ពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ិត ប្រាំង

* * *

ប្រកាសលេខ ៨៨ ផក.ប្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ១ : អនុញ្ញាតអោយក្រុមហ៊ុន ហ្គាន់ដា ខេមបូឌា (GUAN DA CAMBODIA Co., LTD) តំណាងដោយលោក LIU XI ជនជាតិចិន ភេទប្រុស អាយុ ៤២ឆ្នាំ អាស័យដ្ឋាន # ៣៨ GONG NONG RD. NANTONG JIANGSU . CHINA កាន់លិខិតឆ្លងដែន លេខ ៨៨៨៣៦៣ ចុះថ្ងៃទី ២៤ -៩-៩១ «បង្កើតរោងចក្រកាត់ដេរម្ហូកនាំចេញ » ដែលមានឈ្មោះថា «ហ្គាន់ ដា ខេមបូឌា »មានទីតាំងស្ថិតនៅផ្ទះលេខ ៤២៤ CD មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកង ទី១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។

ប្រការ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រ កាត់ដេរម្នាក់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្មរ៉ែ និងថាម ពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវផលិតផល «ម្នាក់អំពីក្រណាត់ » ទៅ តាមគំរូដែលតំកល់ទុកនៅ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៧១ អយក. ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅតិត្តចលភាព

« សំរាប់គ្រូមត្តេយ្យសិក្សា »

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយកប្ល/ទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅវិទ្យាសាស្ត្រអនុវត្តថ្នាក់ទី ២ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅ «ចិត្តចលភាព »សំរាប់គ្រូមត្តេយ្យសិក្សាដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់គណៈកម្មការមត្តេយ្យសិក្សា នៃក្រសួងអប់រំយុវជននិងកីឡា និងអង្គការកុមារកម្ពុជាដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យសិក្សា ។

ប្រការ២ : មន្ទីរនាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ចវិទ្យាស្ថាន ស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៧២ អយក.ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅវិទ្យាសាស្ត្រអនុវត្ត

« សំរាប់សិស្សថ្នាក់ទី២ »

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ន.សរកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣៧៨ អយក.វទអ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅ «ចិត្តបលភាព» ចុះថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៩៧

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពសៀវភៅ «វិទ្យាសាស្ត្រអនុវត្ត »សំរាប់សិស្សថ្នាក់ទី២ ដែលជាស្នាដៃនិពន្ធ របស់គណៈកម្មការវិទ្យាសាស្ត្របឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និងរៀបរៀងដោយអ្នកស្រី អ៊ុង គីមសាន ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ២ : មន្ទីរនាយកដ្ឋានចាត់តាំង លោក ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យនាយក

ដ្ឋានចំនេះទូទៅ និងមន្ត្រីយសិក្សាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមាន ប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨២ អយក. ប្រ.ក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅគីមីវិទ្យា

«សំរាប់សិស្សថ្នាក់ទី៨ »

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតីចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធ អប់រំ
- បានឃើញពិនិតយរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅគីមីឡាថ្នាក់ទី ៨ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅគីមីវិទ្យាសំរាប់សិស្សថ្នាក់ទី ៨ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការគីមីវិទ្យាមធ្យមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវ ក្រសួងអប់រំ យុវជន និងកីឡា និងរៀបរៀងដោយលោក **ស៊ុន ម៉ុណ្ណា** ដើម្បីប្រើប្រាស់នៅតាមសាលារៀន ចំនេះទូទៅ ។

ប្រការ ២ : បន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញវត្ថុ វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយដ្ឋានចំនេះទូទៅ និងមន្ត្រីយសិក្សាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៨៣ អយក. ប្រក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅវិទ្យាសាស្ត្រអនុវត្ត

«សំរាប់គ្រូថ្នាក់ទី២»

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ តុលា ឆ្នាំ ១៩៩៤ កែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ៣១៨ អយក.ឧទន ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅវិទ្យាសាស្ត្រអនុវត្ត ថ្នាក់ទី ២ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសាស្ត្រអនុវត្ត សំរាប់គ្រូថ្នាក់ទី ២ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការវិទ្យាសាស្ត្របឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំយុវជន និងកីឡា និងរៀបរៀងដោយ **អ្នកស្រី អ៊ុង គឹមសាន** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយដ្ឋានចំនេះទូទៅ និងមន្ត្រីយសិក្សាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

តុល .ឡាះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៩២ អយក.ប្រក
ស្តីពីការពង្រីកអនុវិទ្យាល័យបាកានទៅជាវិទ្យាល័យ
បាកាន ក្នុងស្រុក បាកាន ខេត្តពោធិ៍សាត់

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញព្រះរាជក្រឹមលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។
- បានឃើញសារាចរណែនាំ លេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតស្នើរបស់អប់រំ យុវជន និងកីឡា ខេត្ត ពោធិសាត់ លេខ ១១៧១/៩ អយក.ពស ចុះថ្ងៃទី ១៤ កញ្ញា ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តពោធិសាត់ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ពោធិសាត់ ពង្រីកអនុវិទ្យាល័យបាកានបច្ចុប្បន្ន ទៅជាវិទ្យាល័យ បាកាន ចាប់ពីសិក្សា ១៩៩៦-១៩៩៧ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រម ទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃ វិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករង នៃវិទ្យាល័យ មានសិទ្ធិទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករង នៃវិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាន មន្ទីរ អប់រំ យុវជន និង កីឡាខេត្តពោធិសាត់ និង នាយកវិទ្យាល័យ សាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៩៣ អយក. ប្រក

ស្តីពីការបញ្ចូលអនុវិទ្យាល័យពោធិសាត់

ជាមួយ វិទ្យាល័យ ពោធិសាត់ ក្នុងខេត្តពោធិសាត់

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** **ឡើង**ព្រះមហាក្សត្រព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤

-ឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែកក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។

-យោងលិខិតស្នើរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តពោធិសាត់លេខ ១១៧៣/៩ អយក.ពស ចុះថ្ងៃទី ១០ កញ្ញា ១៩៩៦ ដោយមានយោបល់ឯកភាពពីអភិបាលខេត្ត ពោធិសាត់ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មធ្យមសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបញ្ចូលអនុវិទ្យាល័យ ពោធិសាត់ ជាមួយវិទ្យាល័យពោធិសាត់ជាសាលាតែ មួយដែលមានឈ្មោះថា «វិទ្យាល័យ ពោធិសាត់» ចាប់ពីឆ្នាំ ១៩៩៦ -៩៧ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួន ទៀតតាមអង្គការលេខ នៃ វិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយកនាយករង នៃ វិទ្យាល័យ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំនេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិកប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃ ក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត ពោធិសាត់ និង នាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

៤_ ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២០ បទ.ប្រក

ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិភាក្សាលើការទារសុំ
វិនិយោគខាងវិស័យទូរគមនាគមន៍របស់ក្រុមហ៊ុន NTT ប្រទេសជប៉ុន

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម នស.រកម.០៩៩៦.២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលលេខ ០៦ នស ៩៤ ចុះ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការរៀបចំនិងសហប្រតិបត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ និងប្រកាសអោយប្រើ នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.គត ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញលិខិតលេខ ១៣៦៧ សចណ.ចស ចុះថ្ងៃទី ២៧ ខែ ធ្នូ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញលិខិតលេខ ៣៩ ពណ.គប ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
-បានឃើញលិខិតលេខ ០២០ ចុះថ្ងៃទី ០៣ ខែមករា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-បានឃើញលិខិតលេខ ១១៩/៩៧ គ.វ.ក ចុះថ្ងៃទី ២០-០១-៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងដើម្បី ប្រជុំពិភាក្សាការងារស៊ើបអង្កេតលើសេវាទូរស័ព្ទទូទាំងប្រទេសរបស់ក្រុមហ៊ុន NTT ប្រទេសជប៉ុន ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

១-ឯកឧត្តម **ផាន់ គិន** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមមនាគមន៍ ជាប្រធាន

២-ឯកឧត្តម **គួយ គឹមស៊ា** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

៣-ឯកឧត្តម **ឡាំ គួរសាន** អនុរដ្ឋលេខាធិការក្រសួងបៃសណីយ៍ និងទូរគមនាគមន៍ ជាសមាជិក

៤-លោក **សយ សុខា** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី

៥-លោក **សាន ផាន់និ** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៦-លោក **ឡា ណារ៉ាត** ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ សមាជិក

៧-លោក **ឡុង ទ៉ាន់ហាន** ប្រធាននាយកដ្ឋានទូរគមនាមគន៍ក្នុងប្រទេស សមាជិក

៨-លោក **ឈី សុខា** អនុប្រធាននាយកដ្ឋានផែនការគណៈនេយ្យ-ហិរញ្ញវត្ថុ សមាជិក

៩–លោក **គង់ សេង** នាយករងខុទ្ទកាល័យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

១០–លោក **ខាំ រដ្ឋា** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

១១–លោក **សុក ស៊ីផាន់ណា** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ប្រការ ២ : គណៈកម្មការមានភារកិច្ចប្រជុំពិភាក្សាលើកិច្ចសន្យា និងបែបបទផ្សេងៗជាមួយភាគីក្រុមហ៊ុន NTT នៃប្រទេសជប៉ុនលើការងារដូចចែងក្នុងប្រការ១ ។

ប្រការ ៣ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ដោយប្រើប្រាស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាផ្លូវការ ។ ក្រោយពេលការពិភាក្សាប្រធានគណៈកម្មការត្រូវរាយការណ៍ និងសុំយោបល់សម្រេចពីឯកឧត្តមរដ្ឋលេខាធិការ ។

ប្រការ ៤ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច និងសាមីខ្លួនទាំង១១ រូបត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និង ត្រា

សុ ឃុន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២៣ បន

តម្លៃប្រើប្រាស់ទូរស័ព្ទនិងទូរសារប្រើខ្សែដែលផ្គត់ផ្គង់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥–៣–៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១–១២–៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រងតម្លៃ ។

សំរេច

ប្រការ ១ : កំណត់តម្លៃប្រើប្រាស់ទូរស័ព្ទខ្សែដែលផ្គត់ផ្គង់ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីអោយសមស្របទៅតាមបរិមាណនៃការប្រើប្រាស់របស់អតិថិជន ។ តម្លៃប្រើប្រាស់ថ្មីនេះសម្រាប់ការហៅ ទូរស័ព្ទក្នុងទីក្រុងនិងតំបន់នីមួយៗ ហើយនិងទៅបណ្តាខេត្តក្នុង ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : តម្លៃជួលបណ្តាញទូរសព្ទ ១៥ ដុល្លារ ក្នុងមួយខែ ។

ប្រការ ៣ : អនុញ្ញាតិអោយសន្ទនាទូរសព្ទចំនួន ៥០ នាទីក្នុងមួយខែ ជាមួយនិងទូរសព្ទអចល័តទាំងអស់ដែលផ្គត់ផ្គង់ដោយក្រសួងប្រៃសណីយ៍និងទូរមគនាមគន៍ដោយឥតគិតថ្លៃ ។

ប្រការ ៤ : តម្លៃសន្ទនានានាគិតដូចតទៅ ។

ការហៅទៅ	ទូរសព្ទអចលត័	ទូរស័ព្ទចល័ត	ទូរសព្ទអចល័ត	ទូរសព្ទចល័ត
	ក្នុងតំបន់តែមួយ	ក្នុងតំបន់តែមួយ	ឆ្លងតំបន់	ឆ្លងតំបន់(២)
	៣សេនក្នុង១នាទី	៨សេនក្នុង១នាទី	៥០សេនក្នុង១នាទី	៦០សេនក្នុង១នាទី

ប្រការ ៥ : សេចក្តីប្រកាសនេះនឹងចាប់អនុវត្តពីថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៩៧ តទៅ ។

កំណត់ចំណាំ :

(១)និង(២០ : ដោយសារទូរសព្ទចល័តអាចធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទូទាំងប្រទេសបានការគិតគូរតម្លៃត្រូវគិតតាមតំបន់ដែលទូរស័ព្ទត្រូវហៅទៅនោះចុះឈ្មោះ គឺមើលតាមលេខខ្ទង់ទី ៤ និងទី ៥ ជាសញ្ញាសំគាល់ ។ ឧទាហរណ៍ ការហៅពីភ្នំពេញទៅទូរសព្ទចល័តលេខ ១០៥ ៨២០០០១ ដែលជាលេខចុះឈ្មោះនៅខេត្តកំពង់ចាម ត្រូវគិតជាការហៅពីភ្នំពេញទៅកំពង់ចាមជានិច្ច ទោះបីទូរស័ព្ទចល័តនោះ បានចេញពីខេត្តកំពង់ចាមទៅដល់កន្លែងណាផ្សេងក៏ដោយអោយតែនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ហត្ថលេខា និង ត្រា

សូ យុន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០២៤ បន

ស្តីពីការតភ្ជាប់ខោងប្រព័ន្ធទូរស័ព្ទ

រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៤៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ៥.៣.១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សាស្តីពីឋានានុក្រមគ្រប់តម្លៃ ។

សំរេច

១—និយមន័យ

នៅក្នុងបទបញ្ញត្តិនេះ

១.១-កបទក មានន័យថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ដែលជាអង្គភាពគ្រប់គ្រងបទបញ្ញត្តិ ក្នុងវិស័យទូរគមនាគមន៍ ។

១.២-ប្រព័ន្ធទូរស័ព្ទ«ក» ជាប្រព័ន្ធទូរស័ព្ទរបស់អ្នកហៅចេញ ។

១.៣- ប្រព័ន្ធទូរស័ព្ទ (ខ) ជាប្រព័ន្ធទូរស័ព្ទរបស់អ្នកទទួល

១.៤-អចល័ត មានន័យថា ប្រព័ន្ធទូរស័ព្ទដែលចល័តមិនបាន ។

១.៥-ចល័ត មានន័យថា ប្រព័ន្ធទូរស័ព្ទដែលអាចចល័តបាន ។

១.៦-Tyrunk បានន័យថា បណ្តាញតភ្ជាប់រវាងតំបន់ពីរ ឬ រវាងទីក្រុងនិងខេត្ត ។

២-ការតភ្ជាប់រវាងប្រព័ន្ធទូរសព្ទ

២.១-គ្រប់ប្រព័ន្ធទូរស័ព្ទទាំងអស់ត្រូវបញ្ជូនចរន្តសេវាទូរស័ព្ទទាំងអស់អោយដល់ទិសដៅត្រឹមត្រូវ ។

២.២-ប្រព័ន្ធទូរស័ព្ទ «ក» ត្រូវបញ្ជូនលេខទូរស័ព្ទភាគីហៅនិងភាគីទទួលទៅ ប្រព័ន្ធទូរស័ព្ទ «ខ» ។

២.៣-ការភ្ជាប់ឬការបង្រីកបណ្តាញរវាងប្រព័ន្ធពីរ ដោយឆ្លងកាត់ឬមិនឆ្លងកាត់តាមបមាណីកបទក ត្រូវមានការអនុញ្ញាត្តិពី កបទក ជាមុនសិន ។

២.៤-ការផ្តល់និងបម្រើងឧបករណ៍ នៅទីកន្លែងនៃប្រព័ន្ធនិមួយៗជាភារកិច្ចរបស់ម្ចាស់ប្រព័ន្ធនោះ។

៣-ការផ្លាស់ប្តូរប្រព័ន្ធ

៣.១-ម្ចាស់ប្រព័ន្ធដែលមានបំណងកែប្រព័ន្ធដែលអាចតម្រូវអោយមានការកែប្រព័ន្ធ

ម៉្យាងទៀត ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ កបទក អោយបានឆាប់បំផុត ហើយមិនត្រូវអោយតិចជាង ៧ ខែ គិតចាប់តាំងពីថ្ងៃទទួលសំណើរហូតដល់ពេលកំណត់ថ្ងៃត្រូវកែប្រព័ន្ធ ។

៣.២–ដោយសំអាងតាមគោលជំហរអន្តរក្រិតនិងយុត្តិធម៌ កបទកនិងធ្វើការកំណត់ថាភាគីណាត្រូវចេញថ្លៃប្រព័ន្ធ ។

៤–តម្លៃតភ្ជាប់រវាងប្រព័ន្ធទូរស័ព្ទពីរ

៤.១–សន្ទនាទូរស័ព្ទក្នុងតំបន់តែមួយ

ក្នុងការបញ្ជូនចរន្តសេវាទូរស័ព្ទ ពីប្រព័ន្ធទូរស័ព្ទ «ក» ទៅប្រព័ន្ធទូរស័ព្ទ«ខ» ដោយផ្ទាល់ ឬ ដោយឆ្លងកាត់តាមបមាណី កបទក ប្រព័ន្ធទូរស័ព្ទ «ក» ត្រូវបង់ប្រាក់ជូនភាគីនានាដូចតទៅ ៖

៤.១.១–អចល័ត «-----» អចល័ត

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធទូរស័ព្ទ «ខ» X២

៤.១.២–ចល័ត «-----» ចល័ត

ចល័ត «-----» ចល័ត

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធទូរស័ព្ទ«ខ» X ៣

សូមពិនិត្យចំនុច ៤.៤ ចំពោះការសន្ទនាស័ព្ទក្នុងតំបន់តែមួយតែឆ្លងតាម Trunk ពីរ ។

៤.២–សន្ទនាទូរស័ព្ទឆ្លងតបន់កាត់តាម Trunk តែមួយ

ក្នុងការបញ្ជូនចរន្តសេវាស័ព្ទឆ្លងតំបន់ ពីប្រព័ន្ធទូរស័ព្ទ «ក» ទៅប្រព័ន្ធទូរស័ព្ទ«ខ» ដោយផ្ទាល់ ឬ ដោយឆ្លងកាតតាមបមាណី កបទក ប្រព័ន្ធទូរស័ព្ទ«ក» ត្រូវបង់ប្រាក់ជូនភាគីនានាដូចតទៅ ៖

-បានឃើញសេចក្ដីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១-១២-៩១ របស់ក្រុមប្រឹក្សាស្ដីពីឋានានុក្រមគ្រប់តម្លៃ ។

សំរេច

១-និយមន័យ

នៅក្នុងបទបញ្ញត្តិនេះ

១.១-កបទក មានន័យថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ដែលជាអង្គភាពគ្រប់គ្រងបទបញ្ញត្តិ ក្នុងវិស័យទូរគមនាគមន៍ ។

១.២-ប្រព័ន្ធទូរស័ព្ទ«ក» ជាប្រព័ន្ធទូរស័ព្ទរបស់អ្នកហៅចេញ ។

១.៣- ប្រព័ន្ធទូរស័ព្ទ (ខ) ជាប្រព័ន្ធទូរស័ព្ទរបស់អ្នកទទួល

១.៤-អចល័ត មានន័យថា ប្រព័ន្ធទូរស័ព្ទដែលចល័តមិនបាន ។

១.៥-ចល័ត មានន័យថា ប្រព័ន្ធទូរស័ព្ទដែលអាចចល័តបាន ។

១.៦-Tyrunk បានន័យថា បណ្ដាញតភ្ជាប់រវាងតំបន់ពីរ ឱ្យ រវាងទីក្រុងនិងខេត្ត ។

២-ការតភ្ជាប់រវាងប្រព័ន្ធទូរសព្ទ

២.១-គ្រប់ប្រព័ន្ធទូរស័ព្ទទាំងអស់ត្រូវបញ្ជូនចរន្តសេវាទូរស័ព្ទទាំងអស់អោយដល់ទិសដៅត្រឹមត្រូវ ។

២.២-ប្រព័ន្ធទូរស័ព្ទ «ក» ត្រូវបញ្ជូនលេខទូរស័ព្ទភាគីហៅនិងភាគីទទួលទៅ ប្រព័ន្ធទូរស័ព្ទ «ខ» ។

២.៣-ការភ្ជាប់ឬការបង្រីកបណ្ដាញរវាងប្រព័ន្ធពីរ ដោយឆ្លងកាត់ឬមិនឆ្លងកាត់តាមបមាណីកបទក ត្រូវមានការអនុញ្ញាត្តិពី កបទក ជាមុនសិន ។

២.៤-ការផ្ដល់និងបម្រើងឧបករណ៍ នៅទីកន្លែងនៃប្រព័ន្ធនិមួយៗជាភាកិច្ចរបស់ម្ចាស់ប្រព័ន្ធនោះ។

៣-ការផ្លាស់ប្ដូរប្រព័ន្ធ

៣.១-ម្ចាស់ប្រព័ន្ធដែលមានបំណងកែប្រព័ន្ធដែលអាចតម្រូវអោយមានការកែប្រព័ន្ធ

ក្នុងការបញ្ជូនចរន្តសេវាទូរស័ព្ទក្នុងតំបន់តែមួយពីប្រព័ន្ធទូរស័ព្ទ «ក» ទៅប្រព័ន្ធទូរស័ព្ទ «ខ» ដោយផ្ទាល់ ឬ ដោយឆ្លងកាត់តាមបមាណី កបទក ប្រព័ន្ធទូរស័ព្ទ «ក» ត្រូវបង់ប្រាក់ជូនភាគីនានាដូចតទៅ

៤.៤.១–អចល័ត -------- Trunk «---------» Trunk --------- អចល័ត

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធទូរស័ព្ទ «ខ» X ២

៤.៤.២–ចល័ត ----------- Trunk «------» Trunk អចល័ត

ចល័ត ----------- Trunk «-------»Trunk ចល័ត

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធទូរស័ព្ទ «ខ» X ៣

៤.៥–ការសន្ទនាទូរស័ព្ទចេញទៅអន្តរជាតដោយមិនឆ្លងកាត់តាម Trunk

ប្រព័ន្ធទូរស័ព្ទ «ក» ដែលបញ្ជូនចរន្តសេវាទូរស័ព្ទចេញទៅអន្តរជាតិ តាមប្រព័ន្ធអន្តរជាតិទោះបីដោយផ្ទាល់ ឬ ដោយឆ្លងកាត់តាមបរមាណី កបទក ក្តីប្រព័ន្ធទូរស័ព្ទ «ក » ត្រូវបង់ប្រាក់ជូនភាគីនានាដូចតទៅ ៖

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធអន្តរជាតិ X៥

៤.៦–សន្ទនាទូចេញទៅអន្តជាតិដោយឆ្លងតាម Trunk

ប្រព័ន្ធទូរស័ព្ទ « ក » ដែលបញ្ជូនសេវាទូរស័ព្ទចេញទៅអន្តរជាតិតាមប្រព័ន្ធអន្តរជាតិ ដោះបីដោយផ្ទាល់ ឬ ដោយឆ្លងកាត់តាមបរមាណី កបទក ក្តីប្រព័ន្ធ

ទូរស័ព្ទ «ក » ត្រូវបង់ប្រាក់ជូនភាគីនានាដូចតទៅ ៖

–បង់អោយ កបទក X ១

–បង់អោយភាគីអន្តរជាតិ X ៦

ភាគីអន្តរជាតិត្រូវបង់អោយភាគីឯទៀតដូចតទៅ ÷

–ម្ចាស់ Trunk ×៦

៤.៧–ទទួលចរន្តសេវាទូរស័ព្ទមកពីអន្តរជាតិដោយមិនឆ្លងតាម Trunk

ប្រព័ន្ធទូរស័ព្ទ«ខ» ដែលទទួលចរន្តសេវាទូរស័ព្ទពីអន្តរជាតិតាមរយៈភាគីអន្តរជាតិ ភាគីអន្តរជាតិត្រូវបង់ ប្រាក់អោយភាគីនានាដូចតទៅ ៖

–បង់អោយ កបទក X ១

–បង់អោយប្រព័ន្ធទូលស័ព្ទ«ខ » X ៣

៤.៨–ការទទួលចរន្តសេវាទូរស័ព្ទមកពីអន្តរជាតិដោយឆ្លងតាម Trunk

ប្រព័ន្ធទូរសព្ទ «ខ» ដែលទទួលសេវាទូរស័ព្ទមកពី អន្តរជាតិតាមរយៈភាគីអន្តរជាតិ ភាគីអន្តរជាតិត្រូវបង់ប្រាក់អោយភាគីនានាដូចតទៅ ÷

–បង់អោយ កបទក X ១

–បង់អោយម្ចាស់ Trunk X ៦

–បង់អោយប្រព័ន្ធទូរស័ព្ទ «ខ » X ៣

៥–ការគិតតម្លៃដែលត្រូវបង់ត្រូវផ្អែកទៅលើលេខទូរស័ព្ទរបស់អតិថិជន គឺមិនមែនផ្អែក លើទីកន្លែងដែលអតិថិជនកំពង់ប្រើទូរស័ព្ទនោះទេ ។

៦–ការផ្តល់តួលេខ ចំនួននាទីសន្ទនាទូរស័ព្ទ

៦.១–គ្រប់ប្រព័ន្ធទូរស័ព្ទ ទាំងអស់ត្រូវផ្តល់មក កមទក នូវចំនួននាទីសន្ទនាទូរស័ព្ទ សរុប ដែលចេញពីប្រព័ន្ធរបស់ខ្លួននិងខ្លួនទទួលពីប្រព័ន្ធដទៃទៀត មិនអោយលើសពីប្រាំពីរ ថ្ងៃបន្ទាប់ពីដំណាច់ខែនិមួយ ។

៦.២–គ្រប់ប្រព័ន្ធទូរស័ព្ទទាំងអស់ត្រូវផ្តល់មក កបទក នូវទិន្នន័យវិក្ក័យប័ត្រក្នុងលក្ខណៈ ជាខ្សែអាត់ ឬ តាមការបញ្ចូតួលេខតាមបរិបទផ្ទាល់ មិនអោយលើសពីប្រាំពីរថ្ងៃ បន្ទប់ពីដំណាច់ខែនិមួយ ។

៦.៣–ក្រុមប្រព័ន្ធទូរស័ព្ទ និងត្រូវផ្តន្ទាទោសតាមច្បាប់ ក្នុងករណីយ៍ដែលខ្លួនក្លែងបន្លំក្នុងទិន្ន ន័យវិក្កយបត្រ ។

៧–ប្រកាសនេះចាប់អនុវត្តពីថ្ងៃទី១ មីនា ១៩៩៧នេះតទៅ លើកលែងតែងការទូទាត់ដែលទាក់ទងនឹ សេវាអន្តរជាតិការទូទាត់លើសេវាអន្តរជាតិ និង ត្រូវធ្វើតែចំណែកដែលមានការឯកភាពពីភាគី ម្ចាស់ប្រព័ន្ធទូរគមនាគមន៍អន្តរជាតិនោះរួចហើយ ។

៨–ច្បាប់បញ្ញត្តិនេះអាចត្រូវពិនិត្យសារឡើងវិញនៅអនាគត ក្នុងករណីយ៍ចាំបាច់ដែលអាចកើតឡើង ដោយសារការវិវត្តន៍នៃប្រព័ន្ធទូរស័ព្ទ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

សុ ឃុន

* * *

តារាងតម្លៃសេវាទូរស័ព្ទ Xn

Xn	តម្លៃ
	ដុល្លារក្នុងមួយនាទី
X 1	0,00៥
X 2	0,0១
X 3	0,0៥
X 4	0,0៤
X 5	៩២ % *
X 6	0,២0

ហត្ថលេខា និង ត្រា

សុ ឃុន

* * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ១៨៥០ រៀល